# ផ្សិតចំបើង

ផ្សិតចំបើងជាបន្លែសំខាន់សម្បូរជីវជាតិ សម្រាប់បង្កើនមុខម្ហូបអាហារ ធានាបាននូវសុខមាលភាពមនុស្សយ៉ាងល្អប្រពៃ និងកម្លាំងមាំមួន ថែមទៀតជាពិសេសងាយស្រួលលក់ ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារប្រជាកសិករ ។

## ១-ការជ្រើសរើសទីតាំងភូមិសាស្ត្រ

- ក្នុងបណ្តុះផ្សិតចំបើង ចាំបាច់យើងត្រូវជ្រើសរើសទីកន្លែងបណ្តុះផ្សិតចំបើងចាំបាច់យើងត្រូវជ្រើសរើសទីកន្លែងបណ្តុះឱ្យបាន ល្អ ដើម្បីឱ្យផ្សិតដុះលូតលាស់ និង ទទួលបានទិន្នផលខ្ពស់គឺ:
  - ○ ដីស្ងួតមិនជាំទឹក គ្មានសត្វល្អិតបំផ្លាញ
  - ○ មានពន្លឺថ្ងៃគ្រប់គ្រាន់នៅរដូវវស្សា
  - ○ នៅរដូវប្រាំងត្រូវមានម្លប់ឈើងាយស្រួលបណ្តុះផ្សិត
  - ○ រដូវប្រាំងការដាំដុះដំណាំផ្សិត ទទួលនូវការលូតលាស់ល្អ

## ២-ការជ្រើសរើសសម្ភារៈនិងវត្ថុធាតុដើម

### ២.១-សម្ភារៈ

ការបណ្តុះផ្សិតចំបើងចាំបាច់ត្រូវមានសម្ភារៈគ្រប់គ្រាន់ក្នុងការបណ្តុះផ្សិតដូចជា:

- កាំបិត ពូថៅ ចបកាប់ កណ្តៀវ កន្ត្រៃ ។ល។
- ប៉ោតចំពួយផ្កាឈូក - កំបោររស់



- ក្រណាត់កៅស៊ូ ឬ ស្លឹកកណ្តប
- ក្រដាសវាស់ PH

### ២.២-វត្ថុធាតុដើម ចំបើងឬគល់ជញ្ជ្រាំង

### ២.៣-ការថែទាំវត្ថុធាតុដើម

- ការថែទាំវត្ថុធាតុដើមទុក នេះជាការងារមួយ មានសារៈសំខាន់ណាស់ដល់ប្រជាកសិករដែលប្រកបមុខរបរនេះ ។
- ចំបើងត្រូវយកមករៀបគរជាស្នឹមមុនពេលយកមកប្រើពេលប្រើត្រូវបកយកស្រទាប់ខាងលើចោល ។



## -ឥទ្ធិពលលើការបណ្តុះផ្សិតចំបើង

- គេបណ្តុះផ្សិតចំបើងនៅកណ្តាលវាលឬម្លប់ក៏បាន ដោយយោងទៅតាមការនិយមរបស់អ្នកបណ្តុះ
- ចំពោះរដូវក្តៅគួរបណ្តុះក្នុងទីម្លប់ឬធ្វើដំបូលក៏បាន
- ការរៀបចំដីសម្រាប់បណ្តុះវាជាការងារសំខាន់ ព្រោះផ្សិតដុះដោយសារដីមានជីជាតិ ៣០ភាគរយ និង ដុះពីចំបើង៦០ភាគរយ
- ចំពោះរដូវក្រៅផ្សិតដុះដោយសារដីកាន់តែច្រើនឡើង ព្រោះដីបានផ្ទុកអាហារផ្សេងៗសម្រាប់ផ្តល់ឱ្យផ្សិត ។

## ៤-ការកំចាត់សត្វល្អិតនៅក្នុងដី

- ការកំចាត់ពួកសត្វល្អត គឺ កំចាត់ទៅតាមលក្ខណៈបច្ចេកទេសសាមញ្ញឬទៅតាមលក្ខណៈវិទ្យាសាស្រ្តទំនើប ។

### ៤.១-ពពួកសត្វល្អិតក្នុងដីមាន

- ស្រមោច កណ្តៀរ ជន្លេន ដង្កូវដួង

### ៤.២-វិធានការកំចាត់ និងការពារ

វិធានការនេះមានលក្ខណៈខុសប្លែកៗគ្នាទៅតាមបច្ចេកទេសដូចជា:

- ចំពោះដីណាដែលត្រូវការដាំដំណាំផ្សិតគេត្រូវមានវិធីការពារដីនោះកុំឱ្យមានសត្វល្អតរស់នៅ ឬមានមេរោគ ដូច្នេះចំបាច់ត្រូវការ ពារដីនោះ កុំឱ្យមានសត្វល្អិតរស់នៅ ឬមានមេរោគ ដូច្នេះចាំបាច់ត្រូវការពារជាមុន មុននឹងដាំផ្សិតចំបើងគេត្រូវភ្ជួរដីនោះហាលពី ២-៣ ថ្ងៃ ហើយបញ្ចូលទឹក ៣-៤ ថ្ងៃ ទើបបង្ហូរទឹកចេញ



វិញធ្វើរបៀបនេះទើបដីនោះ ពុំមានពពួកសត្វល្អិតឬពួកមេរោគផ្សេងៗរស់នៅបានវិធីនេះ ជាការងារងាយបំផុតហើយពុំសូវអស់ប្រាក់ដែលយើងត្រូវចំណាយ ទៅលើថ្នាំពុល ។

- ប្រើកំបោររស់ជាប្រភេទកំបោរម្យ៉ាងសម្រាប់បំបាត់សត្វល្អិតទាំងនោះបានដែរ ហើយមិនប៉ះពាល់ដល់មនុស្សយើងផង ការប្រើម្សៅកំបោរនេះគេប្រើទៅលើដីផង និងនៅពេលលាយជ្រលក់ចំបើងផងការអនុវត្តន៍ដាំផ្សិតនេះគេត្រូវការកំបោររស់ជាចាំបាច់ណាស់ ។

## ៥-ការរៀបចំដីបណ្តុះផ្សិតចំបើង

- កាប់ដីឱ្យបានជម្រៅ ១០ស.ម - ២០ស.ម
- ហាលដី ២-៣ ថ្ងៃ បំបែកដីឱ្យតូចៗល្មម
- នៅរដូវវស្សាយើងគួរលើករងឱ្យបានកម្ពស់ ១៥ស.ម - ២០ស.ម ។



## ៦-ទឹកដែលត្រូវប្រើក្នុងការបណ្តុះផ្សិតចំបើង

- ជាទូទៅទឹកដែលត្រូវប្រើស្រោចបន្លែបានក៏អាចស្រោចផ្សិតបានដែរ ដូចជា ប្រឡាយ ថ្លុក ត្រពាំង បឹង អូ ជាដើម ជៀសវាង ប្រើទឹកអណ្តូងដែលមានជាតិរ៉ែផ្សេងៗដែលនាំឱ្យផ្សិតដុះលូតលាស់មិនបានល្អ ។

## ៧-ការជ្រើសរើសមេផ្សិតចំបើង

- មេផ្សិតដែលល្អមានក្លិនក្រអូបដូចផ្សិតចំបើងពីតូច
- ថង់មេផ្សិតជាប់លាប់ល្អមិនរហែក
- ថង់មេផ្សិតមានដុះសរសៃៗ ដូចសសៃអំបោះ

## ៨-របៀបរៀបរងបណ្តុះផ្សិតចំបើង

<u>ដំណាក់កាលទី ១</u>

- ទទឹងរង 0.៦0 ម៉ែត្រ ទៅ 0.៧0 ម៉ែត្រ
- ចន្លោះរងសម្រាប់ដើរថែទាំនឹងស្រោចទឹកពី0,៥0ម-0,៧0ម
- បោះបង្គោលក្បាលនៅសងខាងរងដើម្បីទប់ចំបើង





<u>ដំណាក់កាលទី ២</u>

- យកចំបើងឬគល់ជញ្ជ្រាំងដែលបានសម្រាំងទុកជ្រលក់ទឹកឱ្យជោគល្អឬដាក់ត្រាំទឹករយៈពេល ៦ - ១២ម៉ោង រួចស្រង់ចេញពីទឹកយកមកតម្រៀបដោយផ្ទុយគ្នាដាក់ក្បាលកណ្តាប់ចេញក្រៅ ។
- ពេលយើងរៀបមួយស្រទាប់ ហើយត្រូវស្រោចទឹកបណ្តើរជាន់បណ្តើរឱ្យហាប់
- យកមេផ្សិតដែលបានសម្រាំងទុកឈ្លីអោយម៉ដ្ឋយកមករោយតាមបណ្តោយរងដោយឃ្លាតចេញពីគល់កណ្តាប់ពី ៥ស.ម - ៧ស. ម (ត្រូវប្រើមេផ្សិត២ កញ្ចប់ លើរងមាន បណ្តោយ ៥ ម) ។
- បន្ទាប់មករោយអាហារបន្ថែមពីលើមេផ្សិតទៀត អាហារបន្ថែមនោះប្រើ ១ម២ = ១ គីឡូក្រាម (ស្លូត និង រាយល្អ ដែលត្រៀមទុកមួយសប្តាហ៍មុន) ។



- ក្រោយពេលរៀបចំសព្វគ្រប់ត្រូវទុកចោលរយៈពេល ២-៣ថ្ងៃដោយគិតពីថ្ងៃចាប់ផ្តើម

## ៩-របៀបគ្របចំបើងដុត

- បន្ទាប់ពីបានទុកចោលក្នុងរយៈពេល ២-៣ថ្ងៃមក នៅថ្ងៃទី ៣ យើងត្រូវយកចំបើងស្ងួតមកជជុះគ្របពីលើផ្ទៃរង ទាំងមូលឱ្យសព្វ កន្លែងកម្រាស់ពី ៥ស.ម-៧ស.ម រួចចាប់ផ្តើមដុតពីក្រោមខ្យល់ (ដុតចំនួន ៣ កន្លែងក្នុង ១ រង) គឺក្បាលរងកណ្តាល និងចុងរងដុតរួចត្រូវទុកចោលរយៈពេល ១ ថ្ងៃ ។

ថ្ងៃបន្ទាប់បោសផ្ទះចេញអោយស្អាត ប្រសិនបើកន្លែងខ្លះមានផេះក្រាស់ពេកត្រូវបោសអោយស្មើសព្វរង ។ បន្ទាប់ពីបោសផេះរួចទុក ចោលមួយថ្ងៃទៀត នៅថ្ងៃបន្ទាប់ស្រោចទឹកជាន់ឱ្យហាប់ដោយប្រើកំបោររស់ចំនួន 0.៥ គីឡូក្រាម ជាមួយទឹក១00 លីត្រស្រោចពីលើរងយកជីអ៊ុយរ៉េ 0,១0កគ្រ លាយទឹក១0ប៉ោតផ្កាឈូកហើយស្រោចទឹកធម្មតាបន្ថែមទៀត ។





**ដំណាក់កាលទី ៣**

- បន្ទាប់ពីរោយមេផ្សិតហើយ យើងយកចំបើងជ្រលក់ទឹកអោយជោគរួចយកទៅតម្រៀបពីលើផ្ទៃសកម្មភាពដូចសើទីមួយដែរ ត្រូវបន្ថយក្បាលកណ្តាប់ចូលទៅក្នុងបន្តិចប្រមាណពី ៥ស.ម ទៅ ៧ស.ម នៅសង្ខាងរងជុំវិញ (រក្សាកម្ពស់ដដែល) ។
- ការជាន់និងស្រោចទឹកធ្វើតាមលក្ខណៈដូចខាងលើ ក្រោយពីធ្វើសកម្មភាពរួចហើយត្រូវយកមេផ្សិតនិងអាហារបន្ថែមមករោយពីលើជាការបញ្ចប់នៅលើសើទី២ នៅសើទី២នេះត្រូវប្រើមេទ្វេជាពីរស្មើ ៤ កញ្ចប់លើរងប្រវែង ៥ ម ។

**ដំណាក់កាលទី ៤**

- ក្នុងដំណាក់កាលចុងក្រោយនេះយកចំបើងរៀបដូចនៅសើទី ១ និងទី ២ ដែរ ការបន្ថយក្បាលកណ្តាប់ធ្វើដូចនៅសើទី ២ ។
- ប៉ុន្តែនៅជាន់ទី ៣ ជៀសវាងការដាក់ចំបើងក្រាស់ពេកនាំឱ្យផ្សិតដុះពុំរួច ។
- ការស្រោចទឹក និងជាន់បង្ហាប់ធ្វើរបៀបដដែលៗ ។
- រោយមេផ្សិតចំពីលើរងតែម្តង ទុកសង្ខាងរងឱ្យសល់ ៥ស.ម (ប្រវែងបណ្តោយរង ៥ម = ៤កញ្ចប់)
- រោយមេផ្សិតរួចហើយត្រូវយកចំបើងមកតម្រៀបពីលើរងដោយដាក់បណ្តោយរងកម្រាស់ ៥ស.ម - ៧ស.ម ។

- ជជុះចំបើងស្ងួតគ្របពីលើរងឱ្យជិតកម្រាស់ ៧-១០ស.ម ការគ្របរងមាន

លក្ខណៈ ៤ យ៉ាង:

១- គេយកចំបើងគាបដោយឬស្សីធ្វើដូចថែបសម្រាប់គ្រប

២- គេយកកណ្តាប់ដាក់ជាបញ្ឈរផ្អែកផ្ទប់គ្នាឱ្យជិតជុំវិញរង

៣- គេយកចំបើងជជុះរោយ រាយគ្របតែម្តង

៤- គេយកកៅស៊ូចាស់ស្និចពណ៌សស្រអាប់គ្របផ្ទាល់រងហើយគ្របថែម ពីលើ ។

## ១០-វិធីធ្វើជីកំប៉ុស្តសំរាប់ផ្តល់អាហារផ្សិត

- ការផ្សំចំណីអាហារបំប៉ន ការផ្សំចំណីសំរាប់ជំនួយដល់ការបណ្តុះផ្សិតជាការងារ

ចាំបាច់សំរាប់ធ្វើអោយកើនទិន្នផលជាងការដែល មិនដាក់ជីកំប៉ុស្តិ៍ ។

- យើងអាចលៃលកផ្សំចំណីដោយខ្លួនយើងបាន ពីព្រោះនៅក្នុងស្រុកយើងវត្ថុធាតុ

ទាំងនេះងាយនឹងរក។





ក្នុងការផ្សំចំណីយើងត្រូវប្រើវត្ថុធាតុដើមដូចខាងក្រោម:

**<u>របៀបទី ១</u>**

- អាចម៍សេះស្ងួត ២០ គក្រ ច្របាច់ហាលឱ្យស្ងួត
- អាចម៍គោស្ងួត ៣០ គក្រ ច្របាច់ហាលឱ្យស្ងួត
- កំប្លោកស្ងួត ១២ គក្រ ចិញ្ច្រាំឱ្យម៉ដ្ឋហាលឱ្យស្ងួត
- ដើមថ្នាំជក់ស្ងួត ១០ គក្រ ចិញ្ច្រាំឱ្យម៉ដ្ឋហាឱ្យស្ងួត
- សំបកផ្លែឈូក ១៥ គក្រ ចិញ្ច្រាំឱ្យម៉ដ្ឋហាឱ្យស្ងួត
- ស្នូលផ្លែពោតទុំស្ងួត ៥ គក្រ បុកឱ្យម៉ដ្ឋហាលឱ្យស្ងួត

**<u>ការផ្អាប់</u>**

- យើងត្រូវយកវត្ថុធាតុដើមខាងលើដោយច្របល់ចូលគ្នាអោយសព្វហើយគ្របទុករយៈពេល ៧-១៥ថ្ងៃ មុននឹងយកទៅប្រើប្រាស់ បាន ។

**<u>របៀបទី ២</u>**

- យើងយកអង្ករដំណើប ០.៥ គក្រ ត្រាំទឹករយៈពេល ២ម៉ោងហើយស្រង់ហាលឱ្យស្ងួតរួចបុកឬកិនឱ្យម៉ដ្ឋ ។

- មេដំបែរស្រា ១ ខាំ កិនឱ្យម៉ដ្ឋហើយលាយបញ្ចូលគ្នាជាម្សៅដំណើប ហើយច្របល់ជាមួយនឹងមេផ្សិត (វត្ថុធាតុនេះលាយជាមួយ នឹងមេផ្សិត ១២កញ្ចប់) ។

## ១១-ការថែទាំ

មាន ២ របៀប

**របៀបទី ១**

បន្ទាប់ពីស្រោចទឹក ជាន់ឱ្យហាប់ ដុតរួចគ្របចំបើងស្ងួតយកកៅស៊ូបាស់ស្ទិចពណ៌សគ្របលើរងផ្សិត ហើយគ្របថែមពីលើទៀត ធ្វើ ដូចដំបូលទូកគិតពីរៀបមកបាន ៩ ថ្ងៃ យើងមើលឃើញនូវសរសៃប្រទាក់គ្នាពណ៌សប្រផេះដូចសម្បុកពីងពាង ។ នៅពេលនេះយើង

ពិនិត្យមើលបើកន្លែងណាដែលមានសភាពស្ងួត ហើយនៅលើ ប្លាសស្ទិចគ្មានញើសត្រូវស្រោចទឹកលើរងដែលគ្មានញើស រួចគ្របកៅស៊ូវិញហើយបង្ហើបកៅស៊ូផ្នែកខាងក្រោមកម្ពស់ ៥ស.ម ដើម្បីអោយមានខ្យល់ចេញចូលបានល្អពិនិត្យមើលផ្សិតជាប្រចាំ ប្រសិនបើនៅលើរងផ្សិតមានដូចពងត្រីពណ៌ ស១ ត្រូវបន្ថយការស្រោចទឹកព្រោះបើយើងស្រោចទឹកជ្រុលបណ្តាលឱ្យរលួយខូចកូនផ្សិត ។

**របៀបទី ២**

- យើងស្រោចទឹក មួយថ្ងៃម្តង តែប្រសិនបើយើងស្រោចទឹកនៅពេលព្រឹកគឺយើងស្រោចនៅពេលព្រឹករហូត បើសិនជាយើងស្រោច នៅពេលល្ងាច គឺត្រូវស្រោចល្ងាចជារៀងរហូតលុះដល់ពេលប្រមូលផល ការស្រោចនេះគឺស្រោចអោយស្មើដៃជៀសវាងស្រោចម្តងព្រឹកម្តង ល្ងាចនាំឱ្យសំណើមមិនមានភាពទៀងទាត់នៅក្នុងរងផ្សិត ។





ការស្រោចទឹកនេះយើងត្រូវពិនិត្យសំណើមក្នុងរងផ្សិតសិនបើក្នុងរងផ្សិតមានសំណើមខ្ពស់យើងត្រូវផ្អាកការស្រោចទឹក ។

## ១២-ការប្រមូលផល

- ផលិតកម្មផ្សិតត្រូវបានប្រមូលផលជាបន្តបន្ទាប់ភាគច្រើនអនុវត្តនៅពេលព្រឹកមុនម៉ោង ៨ ពេលបេះផ្សិតត្រូវគ្របចំបើងពីលើរងវាដើម្បីឱ្យផ្សិតលូតលាស់ ផ្តល់ជាបន្តបន្ទាប់ទៀត ។
- គួរប្រមូលផលផ្សិតក្នុងលក្ខណៈដែលផ្សិតនៅក្រពុំល្អមានក្បាលស្រួចមុនពេលក្បាលផ្សិតដុះចេញពីស្រោម ។

<u>**កំណត់សំគាល់**</u>

ពេលព្រឹកស្រោចទឹកនៅម៉ោង ៨ បើស្រោចល្ងាចត្រូវស្រោចនៅម៉ោង ៥ ពេលផ្សិតចេញប៉ិចពន្លក (ដូចពងត្រី) ត្រូវយកចំបើងពីលើរងចេញខ្លះ ដើម្បីបន្ថយសីតុណ្ហភាពដែលអាចអោយផ្សិតធ្វើការដុះលូតលាស់បានល្អ។ នៅពេលចាប់ផ្តើមប្រមូលផលមិនត្រូវស្រោចទឹកច្រើនពេកទេ នាំឱ្យផ្សិតខូច ឬ រលួយ ។

- ដាក់ផ្សិតចូលក្នុងទឹកពុះរយៈពេល ៨ នាទីរួចយកចេញពីភ្លើង
- យកទៅចាក់ក្នុងពាង ឬក្រឡា ហើយគ្របឱ្យជិតល្អជៀសវាងកុំឱ្យប៉ះពន្លឺ
- ការធ្វើបែបនេះអាចទុកប្រើប្រាស់បាន៦ខែនៅពេលណាចង់ទទួលទានត្រូវបន្សាបអំបិលជាមុនសិន ។

ជាទូទៅបងប្អូនប្រជាកសិករតែងតែយល់ថាការកែច្នៃផ្សិតនាំឱ្យអស់រសជាតិ ។ជាការពិតណាស់វាក៏អាស្រ័យទៅលើគុណភាពនៃ ការកែច្នៃដែរ ។





## ការប្រមូលផលផ្សិតចំបើង

## ១៣-ការកែច្នៃផលិតផលផ្សិត

របៀបកែច្នៃមាន ២ យ៉ាងដូចខាងក្រោម

### ១៣.១-ធ្វើផ្សិតស្ងួត

- លាងផ្សិតឱ្យស្អាត
- ត្រាំក្នុងទឹកអំបិលដែលកំពុងពុះរយៈពេល៣-៤ នាទី
- ស្រង់ឡើងហើយច្រោះ និងដាក់ហាលថ្ងៃឱ្យផ្សិតស្ងួតល្អ
- ទុកនៅកន្លែងស្អាត ដោយគ្របការពារពីស្រមោច និងសត្វល្អិត

### ១៣.២-ធ្វើជាផ្អកផ្សិត

- លាងអោយស្អាត
- រៀបចំលាយទឹកអំបិលដោយផ្សំទឹក ១លីត្រ លាយអំបិល ៩០០ក្រាមរួចដាំឱ្យពុះ





**ឯកសារយោងៈ**


- ការិយាល័យផ្សព្វផ្សាយខេត្តកណ្តាល
- អង្គការ CRS ស្រុកអង្គស្នួល
- សាលាជាតិកសិកម្មព្រែកលៀប
- បទពិសោធន៍របស់កសិករស្រុកស្អាង និងស្រុកអង្គស្នួល




ម្យ៉ាងទៀតការកែច្នៃរបៀបនេះមិនប៉ះពាល់ដល់ជីវជាតិឡើយ ផ្ទុយទៅវិញគឺទុកសម្រាប់ធ្វើជាអាហាររបស់បងប្អូនបរិភោគបានយូរ ប៉ុណ្ណោះ

**កំណត់សំគាល់**

- ឈ្មោះវិទ្យាសាស្ត្រ: Vovaria Escultenta
- ឈ្មោះអង់គ្លេស: Straw Mushroom

